ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ.............................................................

# សុន្ទរកថា

## ឯកឧត្តម ជា ចាន់តូ អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា និងជាអនុប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ថ្លែងក្នុងពិធីសម្ពោធយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១១-២០២០ ជាផ្លូវការ

**សណ្ឋាគារ Le Royal ភ្នំពេញ នៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១២**

សូមគោរព ៖

- ឯកឧត្តម គាត ឈន់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាតំណាងដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់
- ឯកឧត្តម Kunio Senga អគ្គនាយកនៃនាយកដ្ឋានអាស៊ីអាគ្នេយ៍នៃធនាគារអភិវឌ្ឍន៍អាស៊ី (ADB)
- លោក Putu Kamayana នាយកធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ប្រចាំនៅកម្ពុជា
- ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី និងនាងកញ្ញា ជាទីមេត្រី

ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយនិងកិត្តិយសបំផុត ដោយបានមកចូលរួមក្នុងពិធីសម្ពោធជាផ្លូវការនូវយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១១-២០២០ របស់រាជរដ្ឋាភិបាល ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **គាត ឈន់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាតំណាងដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ។ វត្តមានដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី នាពេលនេះ កាន់តែញ៉ាំងឱ្យពិធីនេះប្រព្រឹត្តទៅកាន់តែឱឡារិក អធិកអធម និងមានអត្ថន័យជ្រាលជ្រៅថែមទៀត ។

ឆ្លៀតក្នុងឱកាសនេះ តាងនាមគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងប្រធានគណៈកម្មាធិការដឹកនាំការរៀបចំនិងការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ខ្ញុំសូមថ្លែងអំណរគុណចំពោះថ្នាក់ដឹកនាំធនាគារអភិវឌ្ឍន៍អាស៊ី ឯកឧត្តម Kunio Senga លោក Putu Kamayana លោក Samiule Tukuafu និងសហការី ដែលបានគាំទ្រដំណើរការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅកម្ពុជារហូតមកដល់បច្ចុប្បន្ន ។ ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរចំពោះក្រុមការងារបច្ចេកទេសអន្តរក្រសួងរបស់រាជរដ្ឋាភិបាល ដែលចូលរួមចំណែកយ៉ាងសកម្មក្នុងការធ្វើបច្ចុប្បន្នកម្មឯកសារយុទ្ធសាស្ត្រនេះ ប្រកបដោយជោគជ័យ ។


ប្រអប់សំបុត្រលេខ ២៥, ផ្លូវលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

**- ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ជាទីគោរព**

**- ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី និងនាងកញ្ញា ជាទីមេត្រី**

ខ្ញុំសូមឆ្លៀតក្នុងឱកាសនេះ ជម្រាបពីប្រវត្តិ សារៈសំខាន់ និងសមិទ្ធផលនៃការអនុវត្ត យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុកន្លងមក ដូចតទៅ ៖

**១/- ប្រវត្តិនៃការរៀបចំឯកសារយុទ្ធសាស្ត្រនេះ**

វិស័យហិរញ្ញវត្ថុត្រូវបានគេចាត់ទុកថា ជាធាតុផ្សំមួយដ៏ចាំបាច់ក្នុងការរួមចំណែកអភិវឌ្ឍ សេដ្ឋកិច្ចនិងសង្គម ព្រោះថានៅពេលដែលវិស័យហិរញ្ញវត្ថុមានដំណើរការល្អ មានភាពរឹងមាំ វិស័យនេះជាអន្តរការិយកម្មកៀរគរប្រភពធនធានហិរញ្ញវត្ថុនៅទំនេរសម្រាប់បំពេញតម្រូវការ ផលិតកម្ម ទ្រទ្រង់ដល់ការរីកចម្រើននៃវិស័យឯកជននិងកំណើនសេដ្ឋកិច្ចជាតិ ប្រកបដោយចីរភាព ។

ដោយយល់ឃើញពីសារៈសំខាន់នេះ នៅឆ្នាំ២០០១ ដោយមានការគាំទ្រផ្នែកជំនួយ បច្ចេកទេសពីធនាគារអភិវឌ្ឍន៍អាស៊ី រាជរដ្ឋាភិបាលបានអនុម័តចក្ខុវិស័យនិងផែនការអភិវឌ្ឍន៍ វិស័យហិរញ្ញវត្ថុឆ្នាំ២០០១-២០១០ ធ្វើជាផែនការយុទ្ធសាស្ត្ររយៈពេលវែង ដើម្បីកំណត់លំដាប់ លំដោយ គោលនយោបាយ និងផែនការសកម្មភាពនានា សម្រាប់គាំទ្រដល់ការអភិវឌ្ឍវិស័យ ហិរញ្ញវត្ថុនៅកម្ពុជាមួយរឹងមាំ ។ ក្នុងដំណាក់កាលទី១នៃការអនុវត្តយុទ្ធសាស្ត្រនេះ យើងសម្រេច បានសមិទ្ធផលសំខាន់ៗទាក់ទងនឹងវិស័យធនាគារ ធានារ៉ាប់រង ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងចីរភាព នៃកំណើនសេដ្ឋកិច្ចជាតិ ។

បន្ទាប់មក នៅឆ្នាំ២០០៦ ក្នុងដំណាក់កាលទី២ ដើម្បីពង្រឹងនិងបន្តនិរន្តរភាពនៃការអភិវឌ្ឍ វិស័យនេះឱ្យកាន់តែស៊ីជម្រៅនិងរឹងមាំថែមទៀត រាជរដ្ឋាភិបាលបានធ្វើបច្ចុប្បន្នកម្មចក្ខុវិស័យ និងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០១-២០១០ ទៅជាយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០០៦-២០១៥ ដើម្បីរំកិលទៅអនុវត្តឱ្យបានគ្រប់ជ្រុងជ្រោយ ចំគោលដៅ អាទិភាពតាមលំដាប់ លំដោយនិងស៊ីចង្វាក់ប្រទាក់ក្រឡាជាមួយវិស័យធនាគារនិងហិរញ្ញវត្ថុ ។សមិទ្ធផលក្នុងដំណាក់កាល នេះ អាចឆ្លុះបញ្ចាំងតាមរយៈការរីកចម្រើននៃវិស័យធនាគារ វិស័យមីក្រូហិរញ្ញវត្ថុ វិស័យធានារ៉ាប់រង ស្ថិរភាពអត្រាប្តូរប្រាក់ ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងកំណើនសេដ្ឋកិច្ច ។

នៅដំណាក់កាលទី៣ ក្នុងឆ្នាំ២០១១ ដោយយល់ឃើញពីសារៈសំខាន់នៃយុទ្ធសាស្ត្រនេះ និងគោលដៅអាទិភាពរបស់រាជរដ្ឋាភិបាលក្នុងការធ្វើពិពិធកម្មនិងទំនើបកម្មសេដ្ឋកិច្ច ដើម្បី លើកកម្ពស់កម្រិតជីវភាពប្រជាជន និងកាត់បន្ថយភាពក្រីក្រនៅកម្ពុជា គណៈកម្មាធិការគោល នយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានសហការជាមួយធនាគារអភិវឌ្ឍន៍អាស៊ីធ្វើបច្ចុប្បន្នកម្ម យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥ ទៅជាយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យ ហិរញ្ញវត្ថុឆ្នាំ២០១១-២០២០ ស្របតាមផែនការសកម្មភាពនៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្មឆ្នាំ២០០៩-២០១៣ របស់រាជរដ្ឋាភិបាល ដើម្បី

បន្តអភិវឌ្ឍប្រព័ន្ធហិរញ្ញវត្ថុមួយរឹងមាំ និងផ្អែកលើគោលការណ៍ទីផ្សារ ដែលជួយកៀរគរនិងបែងចែកធនធាន រួមចំណែកគាំទ្រដល់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពបន្ថែមទៀត ។

ម្យ៉ាងទៀត យុទ្ធសាស្ត្រនេះក៏បានធ្វើបច្ចុប្បន្នកម្មស្របនឹងបរិបទសំខាន់បី គឺ *(១)*- ការរីកចម្រើននៃសេដ្ឋកិច្ចកម្ពុជា ក្រោមបរិយាកាសអំណោយផលនៃស្ថិរភាពនយោបាយ សន្តិភាព និងសន្តិសុខសង្គមក្នុងរយៈពេលមួយទសវត្សរ៍កន្លងមក *(២)*- ការប្រែប្រួលនៃស្ថាបត្យកម្មហិរញ្ញវត្ថុអន្តរជាតិ បន្ទាប់ពីវិបត្តិសេដ្ឋកិច្ចពិភពលោកនាពេលថ្មីៗនេះ និង *(៣)*-តម្រូវការអភិក្រមអភិវឌ្ឍន៍ថ្មីៗ ដើម្បីគាំទ្រកំណើនសេដ្ឋកិច្ចរឹងមាំនិងអន្តរវិស័យរវាងផ្នែកផ្សេងៗនៃសេដ្ឋកិច្ចកម្ពុជា ដែលវិស័យហិរញ្ញវត្ថុដើរតួនាទីគាំទ្រសំខាន់ជាប្រព័ន្ធនិងប្រទាក់ក្រឡាគ្នា ។

## ២/- ខ្លឹមសារនៃការរៀបចំយុទ្ធសាស្ត្រនេះ

ដោយយល់ឃើញពីភាពចាំបាច់និងសារៈសំខាន់ខាងលើ រាជរដ្ឋាភិបាលបានសម្រេចបង្កើតគណៈកម្មាធិការដឹកនាំ និងក្រុមការងារបច្ចេកទេសសម្រាប់អនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០ ដែលមានសមាសភាពអន្តរក្រសួងមកពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជា ក្រសួងពាណិជ្ជកម្ម ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងយុត្តិធម៌ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងគណៈកម្មការមូលបត្រកម្ពុជា ដើម្បីសហការជាមួយធនាគារអភិវឌ្ឍន៍អាស៊ីរៀបចំធ្វើបច្ចុប្បន្នកម្មឯកសារយុទ្ធសាស្ត្រនេះ ។

ការរៀបចំឯកសារយុទ្ធសាស្ត្រនេះ បានផ្តោតការយកចិត្តទុកដាក់ទៅលើទស្សនវិស័យ គោលបំណង ទិសដៅ អាទិភាពគន្លឹះ និងលំដាប់លំដោយនៃសកម្មភាពកំណែទម្រង់ចាំបាច់នានា ។ ឯកសារយុទ្ធសាស្ត្រនេះមានរចនាសម្ព័ន្ធដូចខាងក្រោមនេះ ៖

- **ជំពូកទី១** ស្តីពីទិដ្ឋភាពទូទៅ :ឆ្លុះបញ្ចាំងអំពីទិដ្ឋភាពរួមនិងបញ្ហាគន្លឹះក្នុងវិស័យហិរញ្ញវត្ថុ
- **ជំពូកទី២** ស្តីពីវិស័យធនាគារ : មានប្រព័ន្ធធនាគារ ការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម វិស័យមីក្រូហិរញ្ញវត្ថុ និងភតិសន្យា
- **ជំពូកទី៣** ស្តីពីវិស័យហិរញ្ញវត្ថុមិនមែនធនាគារ :មានវិស័យធានារ៉ាប់រង សោធន និងទីផ្សារទុន
- **ជំពូកទី៤** ស្តីពីអភិបាលកិច្ចនិងរចនាសម្ព័ន្ធទីផ្សារ : មានក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិ គណនេយ្យនិងសវនកម្ម ប្រព័ន្ធទូទាត់ ប្រព័ន្ធប្រាតិភោគ និងការិយាល័យព័ត៌មានឥណទាន
- **ជំពូកទី៥** ស្តីពីការកសាងសមត្ថភាពសម្រាប់វិស័យហិរញ្ញវត្ថុ និង
- **ជំពូកទី៦** ស្តីពីផែនការសកម្មភាពសម្រាប់ការអភិវឌ្ឍឆ្នាំ២០១១-២០២០ ជាបីដំណាក់កាល។

ជារួម ឯកសារយុទ្ធសាស្ត្រនេះមានលក្ខណៈជាផែនការរំកិល និងបានបង្ហាញពីការរីកចម្រើននៃទីផ្សារ បណ្តាញសេវា និងផលិតផលហិរញ្ញវត្ថុថ្មីៗក្នុងប្រព័ន្ធ ហើយក៏ជាមាគ៌ាសម្រាប់អភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅកម្ពុជាឱ្យរឹងមាំ មានលក្ខណៈសមាហរណទៅក្នុងតំបន់ និងគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជាប្រកបដោយចីរភាព ស្របតាមគោលនយោបាយរាជរដ្ឋាភិបាល ។